សង្កាត់ ១ មកជា ឃុំ កំពង់កណ្តាល

សង្កាត់ ២ មកជា ឃុំ ត្រពាំងអំពិល

សង្កាត់ ៣ មកជា ឃុំ កំពង់បាយ

សង្កាត់ ៤ មកជា ឃុំ អណ្តូងខ្មែរ

សង្កាត់ ៥ មកជា ឃុំ ត្រើយកោះ

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណប្ញទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ១៥ អនក្រ
## ស្តីពីការប្តូរឈ្មោះ ពីរូបខេត្ត សង្កាត់
## ក្នុងខេត្ត ព្រៃវែង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

www.pheakdeylaw.com

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្ត ព្រៃវែង មកជាស្រុកកំពង់លាវ ដែលមានទីតាំងរដ្ឋបាល សាលាស្រុកនៅភូមិ លេខ ៤ ឃុំ កំពង់លាវ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះ សង្កាត់ ចំនួន ប្រាំបី ចំណុះទីរួមខេត្ត មកជាឃុំចំនួន ប្រាំបី ចំណុះ ស្រុកកំពង់លាវ គឺ :

សង្កាត់ កំពង់លាវ មកជា ឃុំ កំពង់លាវ

សង្កាត់ ជើងទឹក មកជា ឃុំ ជើងទឹក

សង្កាត់ បារាយណ៍ មកជា ឃុំ បារាយណ៍

សង្កាត់ តាកោ មកជា ឃុំ តាកោ

សង្កាត់ ព្រែកខ្លោង មកជា ឃុំ ព្រែកខ្លោង

សង្កាត់ ពោធិរៀង មកជា ឃុំ ពោធិរៀង

សង្កាត់ ព្រែកអន្ទះ មកជា ឃុំ ព្រែកអន្ទះ

សង្កាត់ ព្រែកជ្រៃ មកជា ឃុំ ព្រែកជ្រៃ

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន**

* * *

www.pheakdeylaw.com